H13

សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

**LICADHO**
CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

# សេចក្តីថ្លែងការណ៍ជាសកលស្តីអំពី សិទ្ធិមនុស្ស

# THE UNIVERSAL DECLARATION OF HUMAN RIGHTS



ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន
ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

# បុព្វកថា

ខ្ញុំសូមថ្លែង នូវសេចក្តីសរសើរ ដោយអំណរគុណដ៏ជ្រាលជ្រៅ និងកក់ក្តៅបំផុត ជូនសមាគម លីកាដូ ដែលមានគំនិតល្អប្រពៃ ផ្តួចផ្តើមស្រាវជ្រាវឯកសារពីសិទ្ធិមនុស្ស សិទ្ធិស្ត្រី សិទ្ធិកុមារជាដើម ដើម្បីបោះពុម្ពផ្សព្វផ្សាយ ជាឧត្តមប្រយោជន៍ជាតិមាតុភូមិកម្ពុជា ។

នរោត្តម សីហនុ

ព្រះរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែមេសា ឆ្នាំ១៩៩៤

# សេចក្តីថ្លែងការណ៍ជាសាកលស្តីអំពីសិទ្ធិមនុស្ស

## កថាដើម

ដោយយល់ឃើញថា ការទទួលស្គាល់នូវសេចក្តីថ្លៃថ្នូររបស់មនុស្សគ្រប់រូប ព្រមទាំងសិទ្ធិស្មើៗគ្នាដែលមិនអាចប៉ះពាល់បានគឺជាមូលដ្ឋាននៃសេរីភាពយុត្តិធម៌ និងសន្តិភាពក្នុងសកលលោក ។

ដោយយល់ឃើញថា ការមិនទទួល និងការប្រមាថមើលងាយសិទ្ធិមនុស្ស បាននាំឱ្យមានអំពើកាចសាហាវព្រៃផ្សៃ ធ្វើឱ្យមនុស្សទាំងអស់ក្តៅក្រហាយ និងស្អប់ខ្ពើមជាទីបំផុត ។

ការប្រកាសបង្កើតនូវពិភពលោកមួយថ្មី ស្តីអំពីសិទ្ធិមនុស្ស ដែលមនុស្សទាំងអស់គ្នាមានសេរីភាព ខាងនិយាយស្តី ខាងជំនឿ និងបានរំដោះអំពីអំពើភេរវភាព និងទុរគតភាពគឺជាសេចក្តីប្រាថ្នា ដ៏ឧត្តុង្គឧត្តមបំផុតរបស់មនុស្ស ។

ដោយយល់ឃើញថា ការលើកស្ទួយសិទ្ធិមនុស្ស ចាំបាច់ត្រូវមានរបបមួយប្រកបដោយសិទ្ធិគ្រប់បែបយ៉ាង ជួយការពារកុំឱ្យមនុស្សត្រូវបង្ខំចិត្តយកការបះបោរ ចលាចល ជាការសំអាងឧត្តមបំផុត ដើម្បីប្រឆាំងតទល់នឹង អំណាចផ្តាច់ការ និងអំពើសង្កត់សង្កិន ។

ដោយយល់ឃើញថាការជំរុញឱ្យមានការពង្រីកទំនាក់ទំនងជាមិត្តភាពរវាង ប្រជាជាតិនានា គឺជាការមួយដែលមានសារសំខាន់ ។

ដោយយល់ឃើញថា ក្នុងធម្មនុញ្ញ ប្រជាជននៃអង្គការសហប្រជាជាតិ បានប្រកាសជាថ្មីនូវជំនឿរបស់គេ ទៅលើសិទ្ធិជាមូលដ្ឋាន ទៅលើសេចក្តីថ្លៃថ្នូរ ទៅលើតំលៃរបស់មនុស្សទូទៅ ទៅលើសមភាពខាងសិទ្ធិរវាងបុរសនិងនារី ព្រមទាំងមានការប្រកាសប្តេជ្ញាឱ្យមានភាពរីកចំរើនខាងសង្គម និងបង្កើតនូវ

លក្ខណ្ឌយ៉ាងប្រសើរ សំរាប់បំអការរស់នៅ ក្នុងបរិបទមួយមានសេរីភាពទូលំទូលាយទៀតផង ។

ដោយយល់ឃើញថា រដ្ឋជាសមាជិកនៃអង្គការសហប្រជាជាតិ សុទ្ធតែបានសន្យាធ្វើសហប្រតិបត្តិការ ជាមួយអង្គការសហប្រជាជាតិ ហើយធានាឱ្យមានការគោរពជាសាកល និងជាក់ស្តែងនូវសិទ្ធិទាំងឡាយរបស់មនុស្ស និងសេរីភាពជាមូលដ្ឋាន ។

ដោយយល់ឃើញថា ទស្សនៈរួមស្តីអំពីសិទ្ធិ និងសេរីភាពទាំងនេះ គឺជាអត្ថប្រយោជន៍ដ៏ខ្ពស់បំផុត ដើម្បីឱ្យរដ្ឋទាំងឡាយបំពេញបានយ៉ាងពេញលេញ ។

**មហាសន្និបាត** ប្រកាសថា សេចក្តីថ្លែងការណ៍ជាសាកលស្តីអំពីសិទ្ធិមនុស្សនេះ ជាឧត្តមគតិរួម ដែលប្រជាជន និងប្រជាជាតិទាំងឡាយត្រូវប្រកាន់យកដើម្បីឱ្យបុគ្គលគ្រប់រូប និងស្ថាប័ននានានៃសង្គម ដែលមានសេចក្តីថ្លែងការណ៍នេះ ជិតជាប់ក្នុងចិត្តរបស់ខ្លួនជានិច្ច ដោយខិតខំតាមរយៈការសិក្សា និងអប់រំ ធ្វើឱ្យបានរីកចំរើននិងល្អណាស់ នូវការគោរពសិទ្ធិ និងសេរីភាព និងធានាតាមវិធានការ ជឿនលឿន ទាំងខាងប្រជាជាតិក្តី ខាងអន្តរជាតិក្តី ឱ្យមានការ ទទួលស្គាល់ និងអនុវត្តជាសាកល ជាក់ស្តែង ទាំងនៅក្នុងចំណោមប្រជាពលរដ្ឋនៃដែនដី ដែលនៅក្រោមការត្រួតត្រា របស់ខ្លួនផង ។

## មាត្រា ១

## សិទ្ធិមានតម្លៃស្មើគ្នា

មនុស្សគ្រប់រូប មានសេរីភាព មានសេចក្ដីថ្លៃថ្នូរ និង សតិសម្បជញ្ញៈដូចៗ
គ្នាតាំងពីកំណើត ហើយគប្បីប្រព្រឹត្តចំពោះគ្នានឹងគ្នា ក្នុងស្មារតីជាបងប្អូន។



## មាត្រា ២

## សិទ្ធិមានសមភាព

ដោយសំអាងទៅលើសេចក្តីថ្លែងការណ៍នេះ មនុស្សទាំងអស់មិនត្រូវបានគេបែងចែកឱ្យខុសៗពីគ្នា ដោយប្រកាន់ទៅលើជាតិសាសន៍ ពណ៌សម្បុរ វណ្ណៈ មានឬក្រ ភាសា សាសនា មតិនយោបាយ ឬជាពលរដ្ឋរបស់ប្រទេសដែលគ្មានឯករាជ្យក៏ដោយ ។



# មាត្រា ៣

## សិទ្ធិរស់រានមានជីវិត និង សន្តិសុខផ្ទាល់ខ្លួន

មនុស្សម្នាក់ៗ សុទ្ធតែមានសិទ្ធិឱ្យខ្លួនរស់នៅបាន ដោយគ្មានការកៀបសង្កត់ និងមានសេចក្ដីសុខដល់ខ្លួនផង ។

ទោះជាមានទោសកំហុសយ៉ាងណា
ខ្ញុំបាត់បង់តែមួយគត់គឺសិទ្ធិដើរហើរ



ទោះជាយ៉ាងណាក៏ដោយ គឺគេជា
មនុស្ស ហើយមិនត្រូវទទួលរង
នូវអំពើឃោរឃៅអ្វីឡើយ



# មាត្រា ៤

## សិទ្ធិប្រាសចាកពីភាពខ្ញុំកញ្ជះគេ

គ្មានជនណាម្នាក់ ត្រូវបានជាប់ជាជិទូញ ឬជាខ្ញុំកញ្ជះ ដាច់ថ្ងៃឡើយ ។



# មាត្រា ៥

## សិទ្ធិរួចផុតពីការទទួលរងទារុណកម្ម

គ្មានជនណាម្នាក់ត្រូវគេបង្ខំ ឱ្យទទួលរងទារុណកម្ម និងអំពើឃោរឃៅ អមនុស្សធម៌ ឬ បន្ថោកបន្ទាបឡើយ ។



# មាត្រា ៦

## សិទ្ធិមាននីតិបុគ្គលិកភាព

ជនគ្រប់រូប សុទ្ធតែមានសិទ្ធិឱ្យគេទទួលស្គាល់ខ្លួនជាមនុស្ស ពេញលក្ខណៈច្បាប់ ទោះបីនៅទីកន្លែងណាក៏ដោយ ។





គឺគ្មានអ្នកណាចាំពួនស្ទាក់វែកឆេរឡើយ ។

# មាត្រា ៧

## សិទ្ធិស្មើភាពចំពោះមុខច្បាប់

មនុស្សគ្រប់រូប សុទ្ធតែមានសិទ្ធិស្មើៗគ្នានៅចំពោះមុខច្បាប់ ហើយច្បាប់ត្រូវតែគ្រប់គ្រង និង ការពារមនុស្សឱ្យបានស្មើៗគ្នា ។



# មាត្រា ៨

## សិទ្ធិពឹងពាក់ស្ថាប័នតុលាការ

បុគ្គលគ្រប់រូប អាចពឹងពាក់ស្ថាប័នតុលាការជាតិ ឱ្យជួយដោះស្រាយ និងទប់ទល់នូវរាល់ការរំលោភសិទ្ធិមនុស្ស ដែលរដ្ឋធម្មនុញ្ញនិងច្បាប់នានាបានទទួលស្គាល់ ។






# មាត្រា ៩

## សិទ្ធិទទួលសេរីភាព

គ្មានជនណាម្នាក់ ត្រូវគេចាប់ខ្លួន ឃុំឃាំង ឬ បណ្តេញចេញក្រៅស្រុក តាមទំនើងចិត្តបានឡើយ ។



# មាត្រា ១០

## សិទ្ធិទទួលភាពយុត្តិធម៌ក្នុងការកាត់ទោស

ជនគ្រប់រូបត្រូវមានសិទ្ធិស្មើគ្នា ក្នុងការស្នើឱ្យតុលាការឯករាជ្យ ពិនិត្យពិច័យ មកលើការចោទប្រកាន់ ឬ ការកាត់ទោសណាមួយ ដោយគ្មានលំអៀង និងជាសាធារណៈ ។



## មាត្រា ១១

## សិទ្ធិទទួលការធានា លើការកាត់ទោសស្របតាមច្បាប់

ជនជាប់ចោទគ្រប់រូបត្រូវសន្មតថា ជាអ្នកឥតទោសពៃរ៍សិន រហូតដល់មានការកាត់ក្ដីត្រឹមត្រូវ និងជាសាធារណៈមួយ ។ គ្មានជនណាមួយត្រូវកាត់ទោស ចំពោះអំពើភ្លេចភ្លាំងរបស់ខ្លួន ដែលគ្មានចែងទុកក្នុងច្បាប់ជាតិ និង អន្តរជាតិឡើយ ហើយក៏មិនត្រូវកាត់ឱ្យធ្ងន់ជាងទោស ដែលខ្លួនបានប្រព្រឹត្តជាដាច់ខាត ។



# មាត្រា ១២

## សិទ្ធិឱ្យមានច្បាប់ការពារតម្លៃរបស់ខ្លួន

គ្មានជនណាម្នាក់ ត្រូវគេជ្រៀតជ្រែកតាមទំនើងចិត្ត ប៉ះពាល់ដល់គ្រួសារ ឬកិត្តិយសរបស់ខ្លួនបានឡើយ ហើយច្បាប់ត្រូវតែមានវិធានការ ដើម្បីការពារនូវសិទ្ធិទាំងឡាយនេះ ។



## មាត្រា ១៣

## សិទ្ធិក្នុងការដើរហើរ

ជនណាក៏ដោយ មានសិទ្ធិដើរហើរ ឬចេញចូល និងតាំងទីលំនៅដោយសេរី នៅក្នុងប្រទេស ឬ ក្រៅប្រទេសរបស់ខ្លួនបាន តាមលក្ខណៈស្របច្បាប់ ។



# មាត្រា ១៤

## សិទ្ធិសុំជ្រកកោន

ជនគ្រប់រូប អាចមានសិទ្ធិសុំជ្រកកោននៅប្រទេសក្រៅបាន បើសិនជាខ្លួនមានការគំរាមកំហែងផ្នែកនយោបាយ ពីសំណាក់រដ្ឋអំណាច ។ សិទ្ធិនេះមិនអាចប្រព្រឹត្តទៅបានឡើយ ប្រសិនបើខ្លួនមានជាប់ទាក់ទិននឹងបទឧក្រិដ្ឋអ្វីមួយ ។



# មាត្រា ១៥

## សិទ្ធិដើម្បីមានសញ្ជាតិមួយ

មនុស្សគ្រប់រូប មានសិទ្ធិសុំចូលសញ្ជាតិណាមួយក៏បាន ។ គ្មានជនណាម្នាក់ត្រូវគេដកហូតសញ្ជាតិតាមអំពើចិត្ត ឬដកហូតសិទ្ធិមិនឱ្យប្តូរសញ្ជាតិបានឡើយ ។



# មាត្រា ១៦

## សិទ្ធិរៀបចំគូស្រករ និងមានគ្រួសារ

ចាប់ពីអាយុពេញវ័យទៅ បុរសនិងស្ត្រីមានសិទ្ធិរៀបអាពាហ៍ពិពាហ៍និងមានគ្រួសារ ទោះបីមានពូជសាសន៍ ឬ សាសនា ខុសគ្នាក៏ដោយ ។ អាពាហ៍ពិពាហ៍អាចសំរេចទៅបាន លុះត្រាតែមានការព្រមព្រៀងរវាងភាគីទាំងឡាយ ។



# មាត្រា ១៧

## សិទ្ធិដើម្បីមានរបស់កម្មសិទ្ធិ

បុគ្គលគ្រប់រូប មានសិទ្ធិដើម្បី មានទ្រព្យសម្បត្តិផ្សេងៗ ហើយគ្មាននរណាម្នាក់មានសិទ្ធិដកហូតទ្រព្យសម្បត្តិរបស់អ្នកដោយរំលោភ និងគ្មានមូលហេតុត្រឹមត្រូវឡើយ ។



# មាត្រា ១៨

## សិទ្ធិដើម្បីមានសេរីភាពខាងជំនឿ

មនុស្សគ្រប់រូប មានសិទ្ធិកាន់សាសនាដោយសេរី និងផ្លាស់ប្ដូរសាសនាដោយសេរី ព្រមទាំងផ្សព្វផ្សាយ ឬ គោរពបូជាសាសនាទាំងនោះតែម្នាក់ឯង ឬ ជាមួយអ្នកដទៃទៀតក៏បាន ។





# មាត្រា ១៩

## សិទ្ធិដើម្បីមានសេរីភាពខាងការនិយាយស្តី ឬ បញ្ចេញមតិ

មនុស្សគ្រប់រូប មានសិទ្ធិក្នុងការបញ្ចេញមតិនិងយោបល់ ហើយគ្មាននរណាម្នាក់អាចជ្រៀតជ្រែក ឬ ហាមឃាត់អ្នកមិនឱ្យនិយាយស្តី ទោះតាមរយៈសៀវភៅ កាសែត វិទ្យុ ទូរទស្សន៍ ឬតាមមធ្យោបាយផ្សេងៗទៀតក៏បាន ។



# មាត្រា ២០

## សិទ្ធិដើម្បីមានសេរីភាពប្រជុំ និងបង្កើតសមាគម

មនុស្សគ្រប់រូប មានសេរីភាពប្រជុំ ឬបង្កើតសមាគម ដោយសន្តិវិធី ។ គ្មានរណាម្នាក់បង្ខំឱ្យចូលរួមក្នុងក្រុម ឬ សមាគមណាមួយដែលគេមិនពេញចិត្តនោះឡើយ ។



# មាត្រា ២១

## សិទ្ធិដើម្បីរួមចំណែក ក្នុងសកម្មភាពនយោបាយ

បុគ្គលគ្រប់រូប មានសិទ្ធិចូលរួមក្នុងកិច្ចការប្រទេសរបស់ខ្លួនដោយធ្វើជារាជការបំរើក្នុងក្រសួងនានាដោយខ្លួនឯង ឬ តាមរយៈតំណាងនិងមានសិទ្ធិចូលរួមបោះឆ្នោត ឬឈរឈ្មោះឱ្យគេបោះឆ្នោតឱ្យដោយសេរី ។



# មាត្រា ២២

## សិទ្ធិដើម្បីមានសន្តិសុខសង្គម

បុគ្គលម្នាក់ៗ មានសិទ្ធិទទួលជំនួយផ្នែកឧបត្ថម្ភពីសង្គមកិច្ច និងមានសិទ្ធិចូលរួមសកម្មភាពខាងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ព្រមទាំងសកម្មភាពផ្សេងៗទៀត ដែលអាចជួយឱ្យរីកចំរើនដល់បុគ្គលិកលក្ខណៈរបស់មនុស្សគ្រប់ៗរូប ។



# មាត្រា ២៣

## សិទ្ធិដើម្បីមានការងារធ្វើ

មនុស្សគ្រប់រូប មានសិទ្ធិដើម្បីមានការងារធ្វើ និងមានសិទ្ធិជ្រើសរើសការងារដោយសេរី ហើយត្រូវទទួលបានប្រាក់កំរៃគ្រប់គ្រាន់សំរាប់រស់ និងគ្រប់គ្រងគ្រួសារខ្លួនឱ្យបានសមរម្យ ។ បុរសនិងស្ត្រីធ្វើការដូចគ្នា ត្រូវបានប្រាក់កំរៃស្មើគ្នា ដើម្បីការពារផលប្រយោជន៍របស់ខ្លួន ។ បុគ្គលម្នាក់ៗមានសិទ្ធិចូលរួម ឬបង្កើតសហជីព ។



## មាត្រា ២៤

## សិទ្ធិដើម្បីមានការសំរាក និងកំសាន្តកាយ

ក្នុងក្របខ័ណ្ឌការងារ បុគ្គលគ្រប់រូប មានសិទ្ធិឈប់សំរាក និងកំសាន្តកាយ ព្រមទាំងមានសិទ្ធិធ្វើការងារក្នុងពេល ម៉ោង ដែលកំណត់សមរម្យត្រឹមត្រូវ និងការឈប់សំរាកដោយមានប្រាក់បៀវត្សរ៍តាមការកំណត់ទៀងទាត់ផង ។



# មាត្រា ២៥

## សិទ្ធិដើម្បីមានជីវភាពរស់នៅសមរម្យ

មនុស្សគ្រប់រូបមានសិទ្ធិ មានជីវភាពរស់នៅសមរម្យ ដើម្បីសុខភាព និងសុខមាលភាពរបស់ខ្លួន ។ នៅក្នុងឱកាសដែលអ្នកគ្មានការងារធ្វើ ឬធ្វើការងារពុំកើត ដោយឈឺ ពិការ ចាស់ជរា មេម៉ាយ ពោះម៉ាយ អ្នកមានសិទ្ធិសុំឱ្យរដ្ឋជួយឧបត្ថម្ភ ។ មាតានិងទារកមានសិទ្ធិទទួលជំនួយ និងថែទាំជាពិសេស ហើយទារកដែលកើតមកមានខាន់ស្លាក្តី ឬគ្មានខាន់ស្លាក្តី មានសិទ្ធិស្មើគ្នាក្នុងការការពារពីសង្គម ។






# មាត្រា ២៦

## សិទ្ធិដើម្បីមានចំណេះវិជ្ជា

មនុស្សគ្រប់រូបមានសិទ្ធិទទួលការអប់រំ ។ ការអប់រំត្រូវតែរៀបចំឡើងដោយឥតយកតម្លៃនៅថ្នាក់បឋមសិក្សា និងមានការអប់រំខាងបច្ចេកទេស និងខាងមុខវិជ្ជាជីវៈត្រូវតែរៀបចំឡើងឱ្យមានជាទូទៅ ។ មាតាបិតាមានសិទ្ធិជាអាទិភាព ជ្រើសរើសប្រភេទសិក្សាដល់បុត្រធីតារបស់គេ ។



## មាត្រា ២៧

## សិទ្ធិអាស្រ័យផលវប្បធម៌ និងអក្សរសិល្ប៍

មនុស្សគ្រប់រូប មានសិទ្ធិចូលរួមដោយសេរី ក្នុងសកម្មភាព ផ្នែកវប្បធម៌ សិល្បៈ និងវិទ្យាសាស្ត្រ ហើយមានសិទ្ធិទទួលបានទ្រព្យភោគផលពីការរីកចំរើននៃផ្នែកទាំងនោះដែលខ្លួនបានបង្កើតឡើង ហើយមានសិទ្ធិទទួលកិច្ចការពារផលប្រយោជន៍ទាំងឡាយ ដែលកើតចេញពីផលិតកម្មខាងវិទ្យាសាស្ត្រ វប្បធម៌ សិល្បៈ និងអក្សរសាស្ត្រ ដែលខ្លួនជាអ្នកបង្កើត ។



# មាត្រា ២៨

## សិទ្ធិដើម្បីការពារ និង ធានាលើសិទ្ធិមនុស្ស

មនុស្សគ្រប់រូប មានសិទ្ធិទាមទារឱ្យមានរបៀបរៀបរយ និងបញ្ញត្តិច្បាប់ នៅក្នុងសង្គម និងនៅក្នុងសកលលោក ដើម្បីឱ្យមានសិទ្ធិនិងសេរីភាព ដែលមានចែងនៅក្នុងសេចក្តីប្រកាសនេះ អាចអនុវត្ត និង សំរេចផលបាន យ៉ាងបរិបូណ៌ ។



# មាត្រា ២៩

## ភារកិច្ចចំពោះសហគមន៍ និងគោរពសិទ្ធិអ្នកដទៃ

បុគ្គលគ្រប់រូប មានភារកិច្ចចំពោះសហគមន៍ដែលខ្លួនរស់នៅ ។ ការប្រើសិទ្ធិរបស់មនុស្សម្នាក់ៗត្រូវមានព្រំដែនច្បាស់លាស់ ដើម្បីកុំឱ្យមានការប៉ះពាល់ដល់សិទ្ធិ និង សេរីភាពអ្នកដទៃ ។ សិទ្ធិនិងសេរីភាពទាំងនោះមិនអាចយកទៅប្រើប្រាស់ផ្ទុយពីគោលបំណង និង គោលការណ៍របស់អង្គការសហប្រជាជាតិបានឡើយ ។





## មាត្រា ៣០
## ការការពារសេចក្ដីថ្លែងការណ៍ឱ្យបានគង់វង្ស

គ្មានរដ្ឋណាមួយ ក្រុមណាមួយ ឬ បុគ្គលណាមួយ មានសិទ្ធិធ្វើសកម្មភាព ប្រព្រឹត្តអំពើសំរាប់បំផ្លាញសិទ្ធិ និងសេរីភាពទាំងឡាយ ដែលមានចែងនៅក្នុងសេចក្ដីប្រកាសនេះឡើយ ។



## សម្ព័ន្ធខ្មែរជំរឿន និង ការពារសិទ្ធិមនុស្ស ដែលហៅកាត់ថា លីកាដូ

គឺជាអង្គការដែលមិនមែនរដ្ឋាភិបាល មិនរកផលកម្រៃ ហើយមិនមែនជាគណបក្សនយោបាយឡើយ ។ អង្គការនេះមានគោលដៅលើកស្ទួយសិទ្ធិមនុស្ស ព្រមទាំងការពារប្រជាពលរដ្ឋនូវអំពើរំលោភសិទ្ធិមនុស្ស ។

ចំណែកពត៌មានផ្សេងៗ សូមអញ្ជើញមកទាក់ទងនៅការិយាល័យ លីកាដូ ស្ថិតនៅផ្ទះលេខ១០៣ ផ្លូវលេខ ៩៧ ខណ្ឌចំការមន ក្រុងភ្នំពេញ ។


**ប្រធាន : លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក**

សូមទំនាក់ទំនងទូរស័ព្ទ : (០២៣) ៣៦០ ៩៦៥ / ៣៦៤ ៩០១

ទូរសារ : (០២៣) ៣៦០ ៩៦៥ / ២១៧ ៦២៦

អ៊ីម៉ែល : licadho@camnet.com.kh


**The Cambodian League for the Promotion and Defense of Human Rights (LICADHO) is a non-governmental, non-profit, apolitical organization, working to promote human rights and protect the population from human rights violations.**

**For further information, please contact LICADHO:**


**President: Dr. PUNG CHHIV KEK**

**# 103, Street 97, Khan Chamcar Mon, Phnom Penh**

**Phone:(023) 360 965 / 364 901**

**Fax: (023) 360 965 / 217 626**

**E-mail:licadho@camnet.com.kh**

# ហាមលក់
# NOT FOR SALE

បោះពុម្ពផ្សាយដោយ

សម្ព័ន្ធខ្មែរជំរឿន និង ការពារ

សិទ្ធិមនុស្ស

Published by the Cambodian League for the Promotion and Defense of Human Rights

ឧបត្ថម្ភដោយថវិការបស់

ណូរ៉ាដ

Published with a grant from

**NORAD**



រក្សាសិទ្ធិដោយអង្គការ **លីកាដូ**
Copyright by LICADHO

បោះពុម្ពលើកទី២ ចំនួន ១២០០០ ក្បាល
ខែ ឧសភា ឆ្នាំ ២០០៣